*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

# ពាក្យបណ្ដឹង

ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១៨

**គោរពជូន**

ប្រធានសាលាដំបូងនៃរាជធានីភ្នំពេញ

មេធាវីតំណាងដោយអណត្តិរបស់ដើមចោទ D ត្រា

អាសយដ្ឋាន: ផ្ទះលេខ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

ដើមចោទ B

ជាន់ទី២៤ អាគារ Phnom Penh Tower ផ្ទះលេខ៤៤៥ ផ្លូវមុនីវង្ស ខណ្ឌ ៧មករា ភ្នំពេញ។

កាវិយាល័យមេធាវី○○○ (កន្លែងដែលត្រូវបញ្ជូន)

មេធាវីតំណាងដោយអណត្តិរបស់ដើមចោទ D

អាសយដ្ឋាន: ផ្ទះលេខ៣៤ សង្កាត់ផ្សារកណ្ដាល ខណ្ឌដូនពេញ ភ្នំពេញ

ចុងចម្លើយ A

រឿងក្ដីទាមទារលែងលះ ជាអាទិ៍

តម្លៃនៃកម្មវត្ថុបណ្ដឹង ៥លាន ៥សែន រៀល

ប្រាក់ប្រដាប់ក្ដីដាក់ពាក្យសុំ ● រៀល

ផ្នែកទី១ សាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១ លែងលះដើមចោទ និង ចុងចម្លើយ។

២ កំណត់ឲ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីច្បង C ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ (កើតថ្ងៃទី២ ខែ៤ ឆ្នាំ២០០៧)។

៣ បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ប្រចាំខែចំនួន ១លានរៀល នៅរៀងរាល់ថ្ងៃចុងខែ

ចាប់ពីខែ៤ ឆ្នាំ២០១៧ ដល់ ខែ៤ ឆ្នាំ២០២៥ ទៅឲ្យដើមចោទ។

៤ បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥០លាន រៀល និងការប្រាក់នៃប្រាក់ចំនួន ៥០ លាន រៀល ក្នុងអាត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំ គិតបន្ទាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ រហូតដល់ពេលបង់ប្រាក់គ្រប់ចំនួន ទៅឲ្យដើមចោទ។

៥ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

ផ្នែកទី២ មូលហេតុនៃការទាមទារ

១ ដំណើរហេតុរហូតដល់រៀបអាពាហ៍ពិពាហ៍ ជាអាទិ៍

ដើមចោទ និង ចុងចម្លើយបានស្គាល់គ្នាតាមការណែនាំរបស់មិត្តភក្តិរួមគ្នា ហើយបាន់ទាក់ទងគ្នាប្រហែលជា ១ឆ្នាំ ក្រោយមកនៅថ្ងៃទី១ ខែ២ ឆ្នាំ២០០៦ ពួកគេបានរៀបអាពាហ៍ពិពាហ៍ និង បានចាប់ផ្តើមជីវភាពអាពាហ៍ពិពាហ៍នៅអាសយដ្ឋានខាងលើរបស់ចុងចម្លើយ។

នៅថ្ងៃទី២ ខែ៤ ឆ្នាំ២០០៧ កូនស្រីច្បង C បានសម្រាល។

២ ការបែងបាក់អាពាហ៍ពិពាហ៍ (មូលហេតុនៃការលែងលះ)

ចុងចម្លើយចូលចិត្តស្រា ហើយនៅក្រោយពេលចាប់ផ្តើមជីវភាពអាពាហ៍ពិពាហ៍ក៏ដោយក៏តែងតែទៅផឹកស្រាជាមួយមិត្តភក្តិពេលត្រឡប់មកពីធ្វើការវិញ។ ចុងចម្លើយតែងត្រឡប់មកផ្ទះវិញពេលយប់ជ្រៅក្នុងសភាពស្រវឹងជោគជាំ ហើយតែងចាយវាយខ្ជះខ្ជាយដោយចេញប្រាក់ថ្លៃស្រាឲ្យមិត្តភក្តិ ជាអាទិ៍។

ដើមចោទមិនធ្វើការងារខាងក្រៅទេ និងខំប្រឹងប្រែងចាត់ចែងប្រាក់ចំណូលដែលបានមកពីចុងចម្លើយសម្រាប់ថ្លៃជីវភាពគ្រួសារ ហើយប្រឹងប្រែងធ្វើការងារផ្ទះ និងមើលថែទាំកូនរហូតមក ប៉ុន្តែ ចុងចម្លើយមិនព្រមសហការទាល់តែសោះ ទោះបីជាថ្ងៃឈប់សម្រាកក៏មិនជួយមើលថែកូនស្រីច្បងដែរ។

ប៉ុន្មានឆ្នាំមុន ចុងចម្លើយកាន់តែផឹកស្រាច្រើនឡើង ហើយពេលថ្មីនេះ ទោះបីជាមិនផឹកស្រាក៏ដោយ ក៏ចុងចម្លើយមានអាការៈមិនស្រួល ហើយអាចសង្ស័យថាមានជម្ងឺញៀនស្រា។ លើសពីនេះ នៅកំឡុងចុងឆ្នាំ២០១៦ ចុងចម្លើយចាប់ផ្តើមប្រើអំពីហិង្សាលើដើមចោទដូចជា វាយទាត់ធាក់ និង រុញខ្លួនផ្ទប់នឹងជញ្ជាំងជាដើម។

កូនស្រីច្បង C នៅតូចនៅឡើយ ហើយតែងបង្ហាញអំពីសភាពភ័យខ្លាចនៅពេលដែលឃើញស្ថានភាពឪពុកស្រវឹង ហើយកូនស្រីច្បង C កាន់តែភ័យខ្លាចខ្លាំងតាំងពីពេលដែលចុងចម្លើយប្រើហិង្សាលើដើមចោទ។

ដូចនេះ ដើមចោទយល់ថា គាត់មិនអាចបន្តជីវភាពអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយទៀតទេ ហើយការរីកលូតលាស់របស់កូនស្រីច្បង C ក៏មិនល្អដែរ ហេតុនេះនៅថ្ងៃទី៥ ខែ

១២ ឆ្នាំ២០១៧ ដើមចោទបាននាំកូនស្រីច្បង C ទៅរស់នៅជាមួយឪពុកម្ដាយខ្លួន និងចាប់ផ្ដើមរស់នៅបែកគ្នាជាមួយចុងចម្លើយ (ក១)។

តាមអង្គហេតុខាងលើ យើងអាចលើកឡើងថាមានមូលហេតុដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានបានក្នុងក្រមរដ្ឋប្បវេណីមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ង។

៣ ការទាមទារសំណងការខូចខាត

ដូចបានរៀបរាប់ខាងលើ ដើមចោទទទួលរងការឈឺចាប់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយគ្មានវិធីណាផ្សេងក្រៅពីលែងលះ ដោយសារតែអត្តចរិកមិនត្រឹមត្រូវហួសហេតុក្នុងជីវភាព និង អំពើហិង្សារបស់ចុងចម្លើយ។ ដើម្បីជាសំណងដល់ការខូចខាតនេះ ចុងចម្លើយត្រូវបង់សំណងការខូចខាតផ្លូវចិត្តយ៉ាងហោចណាស់ ១០លាន រៀល ។

៤ ការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

ដើមចោទទទួលបន្ទុកចិញ្ចឹមបីបាច់ថែទាំកូនស្រីច្បង C ចាប់ពីពេលសម្រាលមកតែខ្លួនឯង ហើយចាប់ពីរស់នៅបែកផ្ទះជាមួយចុងចម្លើយ កូនស្រីច្បង C មានការធំធាត់យ៉ាងត្រឹមត្រូវក្រោមការមើលទាំរបស់ដើមចោទ មិនតែប៉ុណ្ណោះ កូនស្រីច្បង C ក៏ចង់រស់នៅជាមួយដើមចោទផងដែរ។ ផ្ទុយមកវិញ ចុងចម្លើយតាំងពីដើមមកមិនដែលរួមសហការមើលថែកូន និងស្ទើរតែមិនបានចិញ្ចឹមបីបាច់កូននោះទេ។ ហេតុនេះ ការកំណត់ឲ្យដើមចោទមានអំណាចមេបាលើកូនស្រីច្បង C ជារឿងសមហេតុផល។

ហើយបច្ចុប្បន្ន ដើមចោទគ្មានការងារ និងគ្មានប្រាក់ចំណូល និងមិនមានសង្ឃឹមថាអាចរកការងារធ្វើពេលក្រោយបាននោះទេ ផ្ទុយមកវិញ ចុងចម្លើយជាមន្ត្រីរាជការ ហើយមានប្រាក់ ៣លាន រៀល (ក២)។ ដូចនេះ ចុងចម្លើយត្រូវបង់ប្រាក់ចំនួន ១លាន រៀលក្នុង ១ខែ ដើម្បីជាសោហ៊ុយចិញ្ចឹមបីបាច់កូនស្រីច្បង C ទើបសមហេតុផល។

និងមានប្រាក់សន្សំក្នុងគណនីចំនួន ៨០លាន រៀល ដែលដាក់ឈ្មោះរបស់ចុងចម្លើយក្នុងធនាគារឈ្មោះ○○ សាខាឈ្មោះ○○ ប៉ុន្តែតាមការពិតគណនីនេះបានបើកនៅខែ៥ ឆ្នាំ២០០៨ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងទុកសម្រាប់ដាក់ប្រាក់សន្សំដែលដើមចោទចំណាយនៅសល់ពីថ្លៃជីវភាពដែលបានពីប្រាក់ខែរបស់ចុងចម្លើយ។ ហេតុនេះ ទាមទារឲ្យចុងចម្លើយប្រគល់ប្រាក់ពាក់កណ្ដាលចំនួន ៤០លាន រៀល។

៥ អាស្រ័យហេតុនេះ ដើមចោទទាមទារសិទ្ធិអំណាចមេបាលើកូនស្រីច្បង និងលែងលះជាមួយចុងចម្លើយ ជាមួយគ្នានេះ ដើមចោទទាមទារប្រាក់ចំនួន ៥០លាន រៀល ជាសំណងការខូចខាតផ្លូវចិត្តនៃការលែងលះដោយផ្អែកលើការបែងចែកទ្រព្យសម្បត្តិ និងអំពើអនីត្យានុកូល និងការប្រាក់យឺតយ៉ាវតាមអត្រាការប្រាក់តាមការកំណត់ក្នុងក្រមរដ្ឋប្បវ

ណី ៥% ក្នុង ១ឆ្នាំ គិតបន្ទាប់ពីថ្ងៃសាលក្រមចូលជាស្ថាពររហូតដល់បង់ប្រាក់គ្រប់ចំនួន ព្រមទាំងបង់ប្រាក់ដែលជាសោហ៊ុយចិញ្ចឹមបីបាច់កូនក្នុង១ខែចំនួន ១លាន រៀល គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពររហូតដល់កូនក្លាយជានីតិជន ។

## ប្រភេទនៃភស្តុតាង

| | | |
|---|---|---|
| ១ | ភស្តុតាង លេខក១ | លិខិតថ្លែងការណ៍ |
| ២ | ភស្តុតាង លេខក២ | តារាងបញ្ជាក់ប្រាក់ខែ |
| ៣ | ភស្តុតាង លេខក៣ | លិខិតបញ្ជាក់ប្រាក់សន្សំក្នុងគណនី |
| ៤ | ភស្តុតាង លេខក៤ | លិខិតបញ្ជាក់អាពាហ៍ពិពាហ៍ |
| ៥ | ភស្តុតាង លេខក៥ | លិខិតបញ្ជាក់កំណើតរបស់ C |

## ឯកសារភ្ជាប់

| | | |
|---|---|---|
| ១ | សេចក្តីចម្លងពាក្យបណ្តឹង | ១ ច្បាប់ |
| ២ | សេចក្តីចម្លងភស្តុតាងលេខ ក១ និង ក២ | ១ ច្បាប់ គ្រប់លិខិត |
| ៣ | លិខិតប្រគល់សិទ្ធិធ្វើជាអ្នកតំណាងដោយអាណត្តិ | ១ ច្បាប់ |